មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## ២-សេចក្តីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៩៩

### សេចក្តីសំរេចលេខ ៥២ សសរ
### ស្តីពីការបង្កើតគណៈកម្មការសហប្រតិបត្តិការវិស័យថាមពលអគ្គិសនីជាមួយប្រទេស ថៃ ឡាវ វៀតណាម

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងសំណូមពរចាំបាច់របស់រាជរដ្ឋាភិបាល

### សំរេច

ប្រការ ១ : បង្កើតគណៈកម្មការសហប្រតិបត្តិការវិស័យថាមពលអគ្គិសនី រវាងកម្ពុជាជាមួយប្រទេស ថៃ ឡាវ និងវៀតណាម ដែលរួមមានសមាសភាពដូចខាងក្រោម ៖

១-ឯ.ឧ អ៊ិត ប្រាំង រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ជាប្រធាន

២-ឯ.ឧ ម៉ុន អ៊ុយ អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី ជាអនុប្រធាន

៣-ឯ.ឧ ឡុង វិសាលោ អនុរដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក

៤-ឯ.ឧ អ៊ុត ឈន អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក

៥-ឯ.ឧ ប្រាជ្ញ ស៊ុន អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន ជាសមាជិក

៦-ឯ.ឧ សួន សិទ្ធី អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា ជាសមាជិក

៧-ឯ.ឧ នាង ផាត អគ្គនាយក អគ្គនាយកដ្ឋានយោធសេវា ក្រសួងការពារជាតិ ជាសមាជិក

៨-ឯ.ឧ គេង សារឌឿ អគ្គនាយករងនគរបាលជាតិ នៃក្រសួងមហាផ្ទៃ ជាសមាជិក

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ច :

-ពិនិត្យរៀបចំ សំរបសំរួល ការងារកិច្ចសហប្រតិបត្តិការវិស័យថាមពលអគ្គិសនីជាមួយប្រទេសថៃ ឡាវ និងវៀតណាម

-ពិនិត្យឯកសារកិច្ចព្រមព្រៀងសហប្រតិបត្តិការវិស័យថាមពលអគ្គិសនី ដើម្បីដាក់ជូនរាជរដ្ឋាភិបាលសំរេច ។

-តាមដាននិងរាយការណ៍ ជូនរាជរដ្ឋាភិបាល ស្តីពីដំណើរការនៃការអនុវត្តន៍កិច្ចព្រមព្រៀងសហប្រតិបត្តិការ ។

ប្រការ ៣ : គណៈកម្មការមានក្រុមការងារជំនាញមួយជាជំនួយការ ដែលមានការិយាល័យអចិន្ត្រៃយ៍ តាំងនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បណ្តាខេត្តតាមព្រំដែន កម្ពុជា ថៃ កម្ពុជា ឡាវ កម្ពុជា វៀតណាមនិងសាមីជនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃកាលបរិច្ឆេទចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

## ៣-សារាចរ

រាជធានីភ្នំពេញ,ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៩៩

### សារាចរលេខ ០៨ សរ

### ស្តីពីការរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ នៅពេលប្រលង

***

កន្លងមក ការប្រលងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ និង មធ្យមសិក្សាបឋមភូមិ បានទទួលលទ្ធផលល្អមួយកំរិតធំហើយ បើប្រៀបធៀបទៅនឹងលទ្ធភាពដែលយើងមាន និង សភាពការណ៍ជាក់ស្តែងនៃព្រះរាជាណាចក្រកម្ពុជាយើង ។ ប៉ុន្តែយើងនៅមានចំនុចសេសសល់ខ្លះៗ ដែលចាំបាច់ត្រូវកែលំអដូចជា :

-ការបង្កភាពអនាធិបតេយ្យ រំខានដល់ប្រក្រតីភាពនៃការប្រលង ។